# សេចក្តីណែនាំនៃការដាក់ពាក្យប្រឡងចម្រៀងណូដជីម៉ាន់ឆ្នាំ២០២៥

កម្មវិធីប្រឡងចម្រៀងណូដជីម៉ាន់

កាលបរិច្ឆេទ៖

✧ បើកទទួលពាក្យ៖ ថ្ងៃសុក្រ ទី២ ខែឧសភា តាមអនឡាញ

✧ បិទទទួលពាក្យ៖ ថ្ងៃអាទិត្យ ទី៨ ខែមិថុនា

✧ លទ្ធផលវគ្គជម្រុះ នឹងប្រកាសនៅថ្ងៃសុក្រ ទី២០ ខែមិថុនា

✧ វគ្គផ្តាច់ព្រ័ត្រ៖ ថ្ងៃអាទិត្យ ទី១៣ ខែកក្កដា ឆ្នាំ២០២៥ ម៉ោង ១៥:០០-១៧:៣០(អាចកែប្រែ) នៅសាលអង្គរ-គីហ្សូណា CJCC

ការប្រឡងវគ្គផ្តាច់ព្រ័ត្រ នឹងរៀបចំឡើងនៅCJCC ក្នុងឱកាសពិធីបុណ្យផ្កាយ (តាណាបាតា) ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។

➢ ស្វាគមន៍បេក្ខជនដែលមានសញ្ជាតិខ្មែរចូលរួមប្រឡងចម្រៀងណូដជីម៉ាន់២០២៥។ បេក្ខជនអាចប្រឡងចម្រៀងទោល ឬ ប្រឡងជាក្រុម។

ការដាក់ពាក្យសម្រាប់វគ្គជម្រុះ

➢ បេក្ខជនត្រូវបំពេញគ្រប់ចំនុចដែលតម្រូវក្នុង Microsoft Form (https://forms.office.com/r/4GMt7CnDQW)

(ពេលដាក់ពាក្យ ត្រូវតែភ្ជាប់លីងវីដេអូចម្រៀងរបស់ខ្លួន) ឱ្យបានត្រឹមថ្ងៃទី៨ ខែមិថុនា។

➢ លទ្ធផលបេក្ខជនជាប់វគ្គជម្រុះ ដើម្បីចូលរួមការប្រឡងចម្រៀងណូដជីម៉ាន់២០២៥ វគ្គផ្តាច់ព្រ័ត្រ នឹងត្រូវប្រកាសនៅថ្ងៃទី២០ ខែមិថុនា នៅលើគេហទំព័រ និងហ្វេសប៊ុកស្ថានទូតជប៉ុន។

**ដំណើរការនៃវគ្គផ្តាច់ព្រ័ត្រ**

- បេក្ខជនដែលចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ ត្រូវត្រៀមភ្លេងសម្រាប់ច្រៀងនៅថ្ងៃប្រឡងដោយខ្លួនឯង ហើយត្រូវផ្ញើមកកាន់ស្ថានទូតជាមុន ត្រឹមថ្ងៃចន្ទ ទី៣០ ខែមិថុនា។ ការប្រឡងចម្រៀងលើកនេះ មិនមានម៉ាស៊ីនខារ៉ាអូខេដែលអាចមើលឃើញអក្សរចម្រៀងទេ ដូច្នេះ បេក្ខជនត្រូវទន្ទេញចាំបទចម្រៀង ឬត្រៀមណោតទំនុកច្រៀងដោយខ្លួនឯង ហើយច្រៀងលើឆាកតែម្តង។

- បេក្ខជនចូលរួមប្រឡងវគ្គផ្តាច់ព្រ័ត្រ តម្រូវមកកាន់ទីតាំងដើម្បីសម នៅសាលអង្គរ-គីហ្សូណា នៅម៉ោង១៣:៣០ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។
  ពេលវេលាសម ១៣:៣០- ១៤:៣០
  ពេលវេលាប្រឡងចម្រៀង ១៥:០០ -១៧:៣០
  * បញ្ជាក់ម៉ោងខាងលើអាចកែប្រែ។

**ព័ត៌មានលម្អិត**

- សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន
- ទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២)
- អាសយដ្ឋានអ៊ីម៉េល៖ info.jpn@pp.mofa.go.jp